# គម្រោងបំពេញបញ្ចប់ផ្លូវ
# គម្រោងកែលម្អច្រករបៀងផ្លូវ MARKET STREET
# សេចក្តីជូនដំណឹង អំពីការសាងសង់ទីក្រុងឡុងប៊ិច

អ្នកម៉ៅការរបស់ទីក្រុង គឺក្រុមហ៊ុន All American Asphalt គ្រោងនឹងចាប់ផ្តើមការសាងសង់ផ្លូវនៅក្នុងតំបន់ក្នុងនេះ នៅអំឡុងសប្តាហ៍នៃថ្ងៃទី ១ ខែសីហា – ថ្ងៃទី ៥ ខែសីហា ឆ្នាំ ២០២២ ដែលបានគ្រោងទុក ថានឹងបញ្ចប់នៅក្នុងខែសីហា ឆ្នាំ ២០២៣ ដោយមិនគិតពីការរារាំងដោយអាកាសធាតុ ឬការពន្យារពេលដែលមិនបានរំពឹងទុកផ្សេងទៀតឡើយ។ ការងារនឹងប្រព្រឹត្តទៅ៖

**ដំណាក់កាលទី I = ផ្លូវ Market Street រវាង LA River និង Atlantic Avenue**
**ដំណាក់កាលទី II = ផ្លូវ Market Street រវាង ព្រំប្រទល់ផ្លូវ Atlantic and East City**

គម្រោងនេះរួមមានការសាងសង់រនាំងផ្លូវ, ប្រឡាយបង្ហូរ, បន្ទះឡានក្រុង, ចិញ្ចើមផ្លូវ/គុបតែងចិញ្ចើមផ្លូវ, រៀបចំផ្លូវដើរឡើងវិញ, ផ្លាស់ប្តូរទីតាំងប្រព័ន្ធការពារព្យុះ និងក្បាលទឹកពេលមានអគ្គីភ័យ, ភ្លើងសញ្ញាចរាចរណ៍ និងកែប្រែភ្លើងបំភ្លឺផ្លូវ, បោះបង្គោល និងផ្លាកសញ្ញា និងការងារបន្ថែមជាក់ស្តែងផ្សេងៗទៀត។

អ្នកម៉ៅការដាក់កាលបរិច្ឆេទបំពេញការងារ **ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ចាប់ពីម៉ោង ៧:០០ ព្រឹក ដល់ ៣:៣០ រសៀល។** ផ្លាកសញ្ញា "ហាមចត" ជាច្រើន នឹងត្រូវប៉ុស្តិ៍/បិទបង្ហាញ យ៉ាងហោចណាស់បីថ្ងៃមុនពេលចាប់ផ្តើមការងារ។ ក្រុមហ៊ុនប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការរក្សាកន្លែងចតឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន។

មានការចាំបាច់ក្នុងការបិទផ្លូវប្រសព្វបណ្តោះអាសន្ន ដើម្បីបញ្ចប់គម្រោងនេះ។ ខណៈពេលដែលអ្នកម៉ៅការនឹងព្យាយាមបើកផ្លូវឱ្យបានឆាប់តាមដែលវាមានសុវត្ថិភាពក្នុងការធ្វើដូច្នេះ យើងលើកទឹកចិត្តឱ្យប្រើផ្លូវជំនួស ក្នុងអំឡុងពេលម៉ោងធ្វើការ។ អ្នកម៉ៅការលើកទឹកចិត្តប្រជាពលរដ្ឋ ឱ្យ៖

- រក្សាស្ពឹតឱ្យឆ្ងាយពីផ្លូវ និងសកម្មភាពសំណង់
- កាត់បន្ថយបង្ហូរទឹកចេញពីផ្លូវមុខផ្ទះ និងប្រព័ន្ធធារាសាស្ត្រស្រោចសួនច្បារចូលទៅក្នុងផ្លូវ មុនពេល ឬអំឡុងពេលសកម្មភាពសាងសង់

សូមអរគុណទុកជាមុនចំពោះការអត់ធ្មត់ និងកិច្ចសហប្រតិបត្តិការរបស់អ្នកពេញមួយគម្រោងសាងសង់នេះ។

ប្រសិនបើអ្នកមានសំណួរ ឬមានចម្ងល់ទាក់ទងនឹងគម្រោងនេះ សូមទូរស័ព្ទទៅកាន់នាយកដ្ឋានមុខងារសាធារណៈ តាមលេខ (៥៦២) ៥៧០-៦៣៨៣។ សម្រាប់ភាពអាសន្ន សូមទូរស័ព្ទទៅកាន់ Jorge Ortega អគ្គនាយកក្រុមហ៊ុន All American Asphalt Superintendent តាមលេខ (៩៥១)-៧៥៧ ៨០៥៦ ឬ Chaz Kibler មេការក្រុមហ៊ុន All American Asphalt Foreman តាមលេខ (៧១៤) ៣៦៩-៤៥៨០។

This document is available in Spanish, Khmer and Tagalog. (email contactlbpw@longbeach.gov)
Este documento está disponible en español, tagalo y jemer. (email contactlbpw@longbeach.gov)
ឯកសារនេះ អាចរកបានជា ភាសាអេស្ប៉ាញ ភាសាតាហ្គាឡុក និងភាសាខ្មែរ ។ (email contactlbpw@longbeach.gov)
Ang dokumentong ito ay available sa Espanyol, Tagalog, at Khmer. (email contactlbpw@longbeach.gov)